ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ០៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែកញ្ញា ឆ្នាំ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ | ១ |
| ២- | កិច្ចប្រជុំសាឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ | ៣ |
| ៣- | កិច្ចប្រជុំសាឡើងវិញលើសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ | ៤ |
| ៤- | កិច្ចប្រជុំសាឡើងវិញលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា | ៥ |
| ៥- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១១ | ៦ |
| ៦- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៥ |

# សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ដោយយោងតាមស្មារតីនៃគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជារបស់រាជរដ្ឋាភិបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានតាក់តែងសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ដែលមានគោលដៅបង្កើតគណៈកម្មាធិការថ្នាក់ជាតិដើម្បីរៀបចំ និងសម្របសម្រួលផែនការរៀបចំដែនដី និងនគរូបនីយកម្ម សំដៅធានាការអនុវត្តផែនការរៀបចំដែនដីថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ក្រោមជាតិ នៅព្រះរាជាណាចក្រកម្ពុជា ប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌។

ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានចែងឲ្យបង្កើតគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដើម្បីជំរុញឲ្យមានការកែលម្អទីក្រុង និងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា។

យោងតាមច្បាប់នេះ អនុក្រឹត្យលេខ៨៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧ ក៏បានតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងមានគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ និងអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុងជាសេនាធិការ។



ប៉ុន្តែយន្តការដែលត្រូវបានបង្កើតនេះ មិនទាន់ចាប់ផ្តើមដំណើរការផង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ត្រូវបង្កើតឡើងនៅឆ្នាំ១៩៩៩ ដែលមានសមត្ថកិច្ចថ្នាក់ដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជំនួសគណៈកម្មាធិការដែលបានបង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់៕





នៅខែធ្នូ ឆ្នាំ២០០០ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានបង្កើតឡើង ដោយយល់ឃើញថា ការងារដីធ្លីជាការងារអន្តរវិស័យ តម្រូវឲ្យមានការចូលរួមពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដូច្នេះក្រុមប្រឹក្សាគោលនយោបាយដីធ្លីអាចជាយន្តការសម្រាប់ធ្វើការងាររៀបចំដែនដី និងនគរូបនីយកម្មផងដែរ។ ក៏ប៉ុន្តែតាមរយៈការអនុវត្តការងារជាក់ស្តែងកន្លងមក ក្រោយពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមប្រឹក្សាគោលនយោបាយដីធ្លីក៏បានមើលឃើញពីភាពចាំបាច់ដែលតម្រូវឲ្យមានយន្តការអន្តរស្ថាប័នមួយសម្រាប់ការងាររៀបចំដែនដី និងនគរូបនីយកម្ម ព្រោះការងារនេះមានលក្ខណៈស៊ីជម្រៅខាងបច្ចេកទេសច្រើនជាង[១]។

អង្គប្រជុំជំនាញបច្ចេកទេសមិនបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះទេ ដោយស្នើឲ្យមានការសុំសេចក្តីសម្រេចពីថ្នាក់លើសិន ពីព្រោះសេចក្តីព្រាងព្រះរាជក្រឹត្យនេះ ផ្ទុយនឹងមាត្រា៣នៃច្បាប់រៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងនេះ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

## កិច្ចប្រជុំសារឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# អត្តសញ្ញាណកម្មគ្រួសារក្រីក្រ

កាលពីថ្ងៃទី២១ និងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង៨:៣០នាទី និងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **កែវ វិចិត្រ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ខៀវ សាម៉េត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។

សូមរំឭកថា សេចក្តីព្រាងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្របានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩។ អង្គប្រជុំពេលនោះបានសម្រេចបង្កើតក្រុមការងារចង្អៀត ដើម្បីរៀបចំសេចក្តីព្រាងនេះឡើងវិញ។





សេចក្តីព្រាងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្មី ត្រូវបានដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេសដើម្បីពិនិត្យពិភាក្សាឡើងវិញ។ ក្រោយពីបានផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចកែសម្រួលចំណងជើងពី **អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅកម្ពុជា** ទៅជា **អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ** និងកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ មួយចំនួនទៀតដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សានៅមាត្រា១០ នឹងបន្តពិភាក្សានៅពេលក្រោយទៀត៕

# កិច្ចប្រជុំសារឡើងវិញលើសេចក្តីព្រាងច្បាប់ស្តីពី លទ្ធកម្មសាធារណៈ



កាលពីថ្ងៃទី១៤ និងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង៨:៣០នាទី និងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **យូឃាង ថាវរិទ្ធ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ **សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សូមរំឭកថាសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃទី២៥និងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១។ អង្គប្រជុំពេលនោះបានពិនិត្យពិភាក្សាដល់មាត្រា១០ ហើយក៏បានសម្រេចបង្កើតក្រុមការងារ ចង្អៀត ដើម្បីរៀបចំសេចក្តីព្រាងនេះឡើងវិញ ដោយសារមានបញ្ហាទម្រង់និងខ្លឹមសារខ្លះៗ។



សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈថ្មី ត្រូវបានដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេសដើម្បីពិនិត្យពិភាក្សាឡើងវិញ។ ក្រោយពីបានផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង៕

## កិច្ចប្រជុំសារឡើងវិញលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតគណៈស្ថាបត្យករកម្ពុជា



កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **យូឃាង ថាវរិទ្ធ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ប៊ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

សូមរំឭកថាសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃទី១២ ខែវិច្ឆិកា និងថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ ម្តង និងនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១១ ម្តងទៀត។ អង្គប្រជុំនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១១ បានបានសម្រេចឲ្យក្រសួងសាមីយកសេចក្តីព្រាងនេះទៅសម្រួលឲ្យស្របទៅនឹងមាត្រា១៥ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។





សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជាថ្មី ត្រូវបានដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស ដើម្បីពិនិត្យពិភាក្សាឡើងវិញ។ ក្រោយពីបានផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង៕

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែសីហា ឆ្នាំ២០១១*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែសីហា ឆ្នាំ២០១១នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១ ដែលដឹកនាំដោយ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែសីហានេះសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង ០,២% ធៀបនឹងខែមុន និងកើនឡើង ៦,៤% បើធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។ ក្រុមម្ហូបអាហារនៅតែជាកត្តាចម្បងនៃកំណើនសន្ទស្សន៍ថ្លៃខែ **សីហា/កក្កដា** ដែលកើនឡើង ០,៤% និងរួមចំណែក ១០៤% ទៅក្នុងកំណើនសន្ទស្សន៍ថ្លៃសរុប។

➡ ក្រុមទំនិញដែលគួរឲ្យចាប់អារម្មណ៍មានបម្រែបម្រួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ប្រភេទ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ | ប្រភេទ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|---|---|
| ម្ហូបអាហារ | +០,៤% | +៧,៦% | ភោជនីយដ្ឋាន | +០,៦% | +៩,២% |
| ការដឹកជញ្ជូន | -០,៥% | +៨,៥% | | | |

➡ នៅក្នុងក្រុមម្ហូបអាហារ ត្រីស្រស់មានការកើនឡើងខ្ពស់ជាងគេ ២,៦% ធៀបនឹងខែមុន និងមានអត្រារួមចំណែក ១១២% ទៅក្នុងសន្ទស្សន៍ថ្លៃសរុបនៃខែ **សីហា/កក្កដា** ។

* ការវិភាគជាលាយលក្ខណ៍អក្សរជាការដកស្រង់ចេញពីទិន្នន័យចម្បងៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់នៃតារាងទាំង៥ទេ។ ដូច្នេះ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរៀងខ្លួន។
* ព័ត៌មាន និងតួលេខពណ៌បៃតងសំដៅលទ្ធផលល្អប្រសើរ និងពណ៌ក្រហមសំដៅលទ្ធផលសម្រាប់ការថ្លឹងថ្លែង។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងបរទេស សញ្ញាក្បៀសនៅក្នុងអត្ថបទសំណេរតាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (ជា Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០០៩–២០១១

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា[P] | តុលា[P] | វិច្ឆិកា[P] | ធ្នូ | ប្រចាំឆ្នាំ[P] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១ | ៦,៤ | ៧,៥% | ៧,៣% | ៧,២% | | ៦,៤% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ០,៥% | -០,២% | -០,៩% | | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |
| ២០០៩ | ខែដូចគ្នាឆ្នាំមុន | ៨,០% | ៦,២% | -០,៧% | -៣,៩% | -៥,៧% | -៤,៨% | -៣,៩% | -២,៩% | -២,៣% | -១,៥% | ១,៣% | ៨,០% | -០,៧% |
| | ខែមុន | -១,៥% | -០,១% | ១,៣% | ១,០% | ១,០% | ១,៩% | ១,៤% | ០,៧% | ០,៥% | -០,៣% | -០,៦% | -០,១% | |

**P:** តួលេខខែ កញ្ញា តុលា វិច្ឆិកានិងប្រចាំឆ្នាំ ២០១១ ជាតួលេខព្យាកររបស់ក.ស.វ. ( តាមវិធីសាស្ត្រ **DECOMPOSITION** )

### ក្រាហ្វ ១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១០ និង ២០១១ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




ក្រាហ្វ១ បង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នា) ឆ្នាំ២០១០ និងឆ្នាំ២០១១ ។ ក្រាហ្វក៏បង្ហាញផងដែរ នូវតួលេខការព្យាករបីខែទៅមុខនៃអតិផរណា (ធៀបនឹងខែដូចគ្នាឆ្នាំមុន) ។

➡ **អត្រាប្តូរប្រាក់៖**

| *ប្រភេទ* | អត្រា ខែសីហា | *%Δ ធៀបនឹង ខែមុន* | *%Δ រយៈពេល ១២ខែ* | *ប្រភេទ* | អត្រា ខែសីហា | *%Δ ធៀបនឹង ខែមុន* | *%Δ រយៈពេល ១២ខែ* |
|---|---|---|---|---|---|---|---|
| រ/ដុល្លារ | ៤ ០៩៣រ/១ដុល្លារ | –០,២% | –៣,៤% | បាត/ដុល្លារ | ៣០,០ បាត/១ដុល្លារ | +១,០% | –៤,១% |
| រ/បាត | ១៣៦រ/១បាត | –១,៤% | +០,៧% | ដុង/ដុល្លារ | ២០ ៨៣០ ដុង/ដុល្លារ | +១,៥% | +៦,៨% |
| រ/ដុង | ០,១៩៦រ/១ដុង | –១% | –៩,៧% | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ**នាខែសីហា ឆ្នាំ២០១១ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

- ***ចំណូលថវិកាជាតិ អនុវត្តបានចំនួន ៥២២,០ ពាន់លានរៀល*** *(មធ្យមប្រចាំខែ៩១% នៃគម្រោង) ក្នុងនោះ* ***ចំណូលមូលធន ៥,៧ ពាន់លានរៀល*** ( មធ្យមប្រចាំខែ ៩៥% នៃគម្រោង) និង **ចំណូលចរន្ត ៥១៦,២ ពាន់លានរៀល** (មធ្យមប្រចាំខែ ៩១% នៃគម្រោង)។
- បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ** កើនឡើង ២% និងកើនឡើង ១២% ក្នុងរយៈពេល១២ខែ។ **កំណើន ១២%** នៃចំណូល *ធៀបនឹងខែដូចគ្នាឆ្នាំមុន* បណ្តាលមកពីការកើនឡើងនៃចំណូលចរន្ត ១២% និងចំណូលមូលធន ៤៦% ។

### ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១០ និង ២០១១



- នៅក្នុងចំណូលចរន្ត៖
  - ✓ ចំណូលសារពើពន្ធកើនឡើង ៣% បើធៀបនឹងខែមុន និងកើនឡើង ១៣% ក្នុងរយៈពេល ១២ខែ។ កំណើននៃចំណូលសារពើពន្ធ ធៀបនឹងខែដូចគ្នាឆ្នាំមុន ជាចម្បងបណ្តាលមកពី ពន្ធ-អាករគយ កើនឡើង២៣% រីឯចំណូលពន្ធដារកើនឡើង ៧%។
  - ✓ ចំណូលមិនមែនសារពើពន្ធថយចុះ ៥% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ *គួរកត់សម្គាល់លើកំណើនដ៏គំហុកនៃចំណូលមិនមែនសារពើពន្ធ ដែលបានពីអាកាសចរណ៍ស៊ីវិល ដោយសារតែការបញ្ជូនសាច់ប្រាក់មកវេនាជាតិមានលក្ខណៈបង្គរ។*

| ក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល១២ខែ) | | ក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលរយៈពេល១២ខែ) | |
|---|---|---|---|
| ➢ ពន្ធ-អាករគយ: +២% | ( | ➢ នេសាទ : -៨៩% | (-៥៤%) |
| ➢ ចំណូលពន្ធដារ: +១៨% | +២៣%) | ➢ រុក្ខាប្រមាញ់ : -៨៦% | (-៩៤%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: +១១% | (+៧%) | ➢សម្បទានរ៉ែ : -៥៦% | (+៨%) |
| ✧ កាស៊ីណូ : +៨៩% | (+៤%) | ➢ អាកាសចរណ៍ស៊ីវិល : +១៦៦០% | (+១០%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +៤១% | (+១៤%) | ➢ ផលទុនទេសចរណ៍ : +៨៦% | (+៥៧%) |
| ✧ គ្រប់គ្រង និងទិដ្ឋាការនាំចេញ : -១២% | (-៦២%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +៥៧% | (+១៥៨%) |
| | (+២៥%) | ➢ អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ) : -៣២% | (+១៦%) |
| | | ➢ ចំណូលផ្សេងទៀតពុំមែនសារពើពន្ធ : -៣២% | (+៩%) |

- ***ចំណាយថវិកាជាតិ*** អនុវត្តបាន ៧៥៩ ពាន់លានរៀល ( *មធ្យមប្រចាំខែ ៦៦% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៦១៦ពាន់លានរៀល ( *មធ្យមប្រចាំខែ ៩៩% នៃគម្រោង*) និង**ចំណាយមូលធន**មានចំនួន ១៤៣ ពាន់លានរៀល( *មធ្យមប្រចាំខែ ២៦% នៃគម្រោង*) ។
- *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិកើនឡើង** ៥១% និង**កើនឡើង ២០%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើងនៃចំណាយថវិកាជាតិក្នុងខែនេះបណ្តាលមកពីចំណាយចរន្ត***កើនឡើង ៥៨%*** និងបើធៀបនឹងខែដូចគ្នា ឆ្នាំមុន ចំណាយចរន្ត***កើនឡើង ៣៨%*** ។
- ***តុល្យភាពថវិកាជាតិនៃខែសីហាមានឱនភាព ២៣៧ ពាន់លានរៀល*** ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ ស្ថានភាពរូបិយវត្ថុ ក្នុងខែសីហា ឆ្នាំ ២០១១ មានលក្ខណៈដូចខាងក្រោម៖

- **រូបិយវត្ថុទូទៅ** $M_2$ មានចំនួន***២២ ៦៨២ ពាន់លានរៀល***កើនឡើង ១,៥%ធៀបនឹងខែមុន និងកើនឡើង ២១%ក្នុងរយៈពេល ១២ខែ។

**កំណើន M₂** ធៀបនឹងខែមុន បណ្តាលមកពីការកើនឡើងនៃសូចនាកររូបិយវត្ថុទាំងអស់ ដែលក្នុងនោះ រូបិយវត្ថុក្រៅធនាគារ កើនឡើង ១,៦% ប្រាក់បញ្ញើចរន្ត កើនឡើង ១៥% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ កើនឡើង ៥,៣% និង ប្រាក់បញ្ញើជារូបិយប័ណ្ណ កើនឡើង ១,២%។

យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែសីហា ប្រាក់រៀល**ក្នុងសេដ្ឋកិច្ច**មានចំនួន ១៧,៨% នៃរូបិយវត្ថុ M₂ និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨២,២%។

## ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ ខែសីហា ២០១១




## សមាមាត្រ រវាងចំនួនប្រាក់រៀល និងការផ្គត់ផ្គង់រូបិយវត្ថុ M₂

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុប នៅក្នុង និងក្រៅធនាគារ | ១៨,៣% | ១៩,១% | ១៩,២% | ១៩,១% | ១៨,៥% | ១៨,០% | ១៧,៦% | ១៧,៨% | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,៧% | ១៦,០% | ១៦,៧% | ១៦,៦% | ១៥,៧% | ១៥,២% | ១៤,៩% | ១៤,៩% | | | | |

## បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែ សីហា ២០១១ : ក្នុងវង់ក្រចកជា បម្រែបម្រួលរយៈពេល១២ខែ




**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន **២៩៣៧លានដុល្លារ** កើនឡើង ៣,៨% បើធៀបនឹងខែមុន និងកើនឡើង ២៥%ក្នុងរយៈពេល ១២ខែ។

***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** មានចំនួន **៧ ៧៧៩ ពាន់លានរៀល** ថយចុះ ១,៥% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២% ក្នុងរយៈពេល ១២ខែ។

***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** ( មិនទាន់មានតួលេខ )

***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** ( មិនទាន់មានតួលេខ )

*អត្រាការប្រាក់ប្រចាំឆ្នាំ នាខែសីហា៖*

| ប្រភេទអត្រាការប្រាក់ | អត្រា | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៥២% | 0% | –១% |
| ▪ កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៥,៦៥% | -៣0% | –៣១% |
| ▪ បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៦% | +២,៥% | 0 |
| ▪ កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៤,៩% | -១១% | –៨% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ ក្នុងខែសីហា ឆ្នាំ២០១១ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

**កសិកម្ម៖**

✓ ផលិតកម្មនេសាទមាន **៣៩ ពាន់តោន** កើនឡើង ៥% បើធៀបនឹងខែមុន និងកើនឡើង ៣0% ក្នុងរយៈពេល ១២ខែ។

**ឧស្សាហកម្ម៖**

✓ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២២៩ លានគីឡូវ៉ាត់ម៉ោង កើនឡើង ១% បើធៀបនឹងខែមុន និងកើនឡើង ១៦% ក្នុងរយៈពេល ១២ខែ។

✓ អគ្គិសនីផ្គត់ផ្គង់ដោយវ៉ារីអគ្គិសនីមានចំនួន ៩ លានគីឡូវ៉ាត់ម៉ោង កើនឡើង២១៨% បើធៀបនឹងខែមុន និងកើនឡើង ២០៨% ក្នុងរយៈពេល ១២ខែ។

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើង : មិនទាន់មានតួលេខ

✓ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន –សីហា២០១១ | ចំនួន–កក្កដា២០១១ | ចំនួន–សីហា២០១០ |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | មិនមានតួលេខ | ៨ | ៩ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២១ | ១៧ | ១២ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៧ | ១៨ | ១៤ |

**សំណង់៖**

✓ **សំណង់អនុញ្ញាតឲ្យសាងសង់**ក្នុងខែសីហា មានចំនួន ៣៨២ ពាន់ម² ថយចុះ ១% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៥៣% ក្នុងរយៈពេល១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ១៣៤ លានដុល្លារ កើនឡើង២២% បើធៀបនឹងខែមុន និងកើនឡើង១៥៤% ក្នុងរយៈពេល ១២ខែ។

✓ **សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះ គឺលំនៅឋាន (៧៣% នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

| ប្រភេទ | ផ្ទៃក្រលា ពាន់ម² –សីហា២០១១ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ លំនៅឋាន | ២៧៩ | +៣% | +២១៩% |
| ▪ ឧស្សាហកម្ម | ៦៥ | -១៥% | +១៦៩% |
| ▪ ពាណិជ្ជកម្ម | ៩ | +៥0% | +២0២% |
| ▪ ទេសចរណ៍ | ៦ | -៦៦% | -៤៦% |

### ការងារ៖

| ប្រភេទ | ចំនួន–សីហា២០១១ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ៣ ៣៤៣ | +៥៣% | –១៧% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៣ ៦១២ | +៤២% | +៨% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១ ៣៩៣ | +៧៩% | +១៥% |
| អ្នកទទួលបានការងារក្រៅប្រទេស | ២ ២១៩ | +២៦% | +៥% |

### វិនិយោគ៖

✓ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./គ.អ.ក. (ថ្មីនិងពង្រីក) ក្នុងខែសីហា មានចំនួន **១២** ដែលគិតជាទុន វិនិយោគស្មើនឹង **៣៣លានដុល្លារ** ។ គម្រោងទាំងនេះអាចបង្កើតការងារឲ្យពលករបាន **១៩ ពាន់នាក់**។

| ប្រភេទ | សីហា២០១១ | កក្កដា២០១១ | សីហា២០១០ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៣៣ | ២ ៦៥០ | ២៨៥ |
| វិស័យកសិកម្ម និង កសិឧស្សាហកម្ម | 0 | ១៥៧ | ២៧៦ |
| វិស័យឧស្សាហកម្ម | ៣៣ | ២ ២៨៦ | ៩ |
| វិស័យទេសចរណ៍ | 0 | ២០៦ | 0 |
| វិស័យហេដ្ឋារចនាសម្ព័ន្ធ និង ផ្សេងៗ | 0 | ២ | 0 |
| **ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន)** | ១២ | ២១ | ១២ |
| **ចំនួនពលករ (ពាន់នាក់)** | ១៩ | ១៩ | ២០ |

### សេវាកម្ម និងទេសចរណ៍៖

✓**ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន–សីហា២០១១ | ចំនួន–កក្កដា២០១១ | ចំនួន–សីហា២០១០ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៨៥ | ២៩៣ | ២២៤ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១ | ៥ | ៤ |
| ▪ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៣៣២ | ៣០៨ | ២៨៨ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ) មានចំនួន ៤៣៨ ពាន់តោន ថយចុះ ៣% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង ៣១% ក្នុងរយៈពេល ១២ខែ ក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល១២ខែ | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ : +៤% | (+២២%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង : -៥% | (+៧៣៨%) |
| ▪ កំពង់ផែកំពង់សោម : -១៤% | (0%) | ▪ កំពង់ផែឧកញ៉ាម៉ុង : +៤៣% | (-៤%) |

**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍**

| *ប្រភេទ* | *ចំនួន(ពាន់នាក់)* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១០ | +៤៣% | +១% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ |
| ▪ ចំនួនអ្នកទេសចរជាតិចេញក្រៅប្រទេស | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ |
| ▪ ចំនួនអ្នកទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាខែសីហាមានចំនួន ២ ១១៧ ពាន់លានរៀល បើធៀបនឹងខែមុន ថយចុះ ៣% ប៉ុន្តែកើនឡើង ២០% ក្នុងរយៈពេល ១២ខែ ក្នុងនោះ៖

| *ទំនិញ* | *%Δធៀបនឹងខែមុន* | *%Δ១២ខែ* | *ទំនិញ* | *%Δធៀបនឹងខែមុន* | *%Δ១២ខែ* |
|---|---|---|---|---|---|
| ប្រេងសាំង | +៥,៧% | +៦% | ប្រេងម៉ាស៊ូត | −១៦% | +៨% |
| ឧស្ម័ន | +២២% | +៧% | ប្រេងខ្មៅ | −២៧% | −២១% |
| គ្រឿងអេឡិចត្រូនិក | +១៨% | +៩៥% | ដែកសំណង់ | −៤៩% | −៦៨% |
| អគ្គិសនី | 0% | +១៦% | ស៊ីម៉ង់ត៍ | −៤% | +២១% |
| ម៉ូតូ | +១៤% | +៦៩% | ជីនិងថ្នាំកសិកម្ម | −១៩% | +១១% |
| រថយន្តសរុប (ព.ល.រ) | −១៣% | +២៩% | គ្រាក់ទ័រនិងគោយន្ត | −១២% | +៦៤% |
| រថយន្តសរុប (គ្រឿង) | −១០% | +៤៤% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | −៦% | +៣៤៩% |

➡ **ការនាំចេញ** ក្នុងខែសីហាឆ្នាំ២០១១ មានចំនួន ១ ៨៦៨ ពាន់លានរៀល (៨៨% នៃការនាំចូល) ថយចុះ ១៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៩%ក្នុងរយៈពេល ១២ខែ ក្នុងនោះ មុខទំនិញសំខាន់ៗមួយចំនួនមាន៖

| *ទំនិញ* | *%Δធៀបនឹងខែមុន* | *%Δ ១២ខែ* | *ទំនិញ* | *%Δធៀបនឹងខែមុន* | *%Δ ១២ខែ* |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | −៥៨% | −៩៨% | វាយនភណ្ឌនិងស្បែកជើង | −៣៤% | −១% |
| កៅស៊ូ | −២០% | +៣៩% | អង្ករ | −៥១% | +៥៨% |
| ផលិតផលនេសាទ | −១% | +៨៧៦% | | | |

➡ ក្នុងខែសីហាឆ្នាំ២០១១នេះ ជញ្ជីងពាណិជ្ជកម្មកម្ពុជាមាន*ឱនភាពចំនួន ២៤៨ ពាន់លានរៀល ស្មើនឹង ៦១ លានដុល្លារ ស.រ.អ.។*

## ៦. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែសីហា ឆ្នាំ២០១១នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | រយៈពេល១២ខែ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ពន្ធលើឈ្នួលផ្ទះ-ដី | -៤% | -១៤% | — |
| ២ | អាករលើតម្លៃបន្ថែម | -៩% | -២៧% | — |
| ៣ | ចំណូលពីនេសាទ (មិនមែនសារពើពន្ធ) | -៨៩% | -៥៤% | មានការធ្លាក់ចុះខ្លាំងនៃចំណូលពីនេសាទ ប៉ុន្តែផលិតកម្មនេសាទបែរជាកើនឡើង ៥%ធៀបនឹងខែមុន និងកើនឡើង ៣០% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តារាង៤)។ |
| ៤ | គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក. (លានដុល្លារ) | -៩៩% | -៨៩% | — |
| ៥ | នាំចេញផលិតផលនេសាទ | -១% | +៨៧៦% | — |

## ៧) ស្ថានភាពអន្តរប្រជុំ និងសន្និដ្ឋាន

### *អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១) ក្នុងខែសីហា ឆ្នាំ២០១១នេះ កំណើនសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់បានចុះមកអត្រាទាបវិញគឺត្រឹមតែ ០,២% ធៀបនឹងខែកក្កដា និង ៦,៤% ធៀបនឹងខែសីហាដូចគ្នា ឆ្នាំ២០១០។ យើងសង្កេតឃើញថា ក្នុងអំឡុង៥ឆ្នាំចុងក្រោយ ទំនិញបីមុខគឺ៖ ភោជនីយដ្ឋាន សាច់ជ្រូក និងត្រីស្រស់ មានការឡើងថ្លៃខ្លាំង និងមានការរួមចំណែកខ្ពស់ ទៅលើអតិផរណានៃសេដ្ឋកិច្ចកម្ពុជា។

២) ចំណូលពន្ធដារ នាខែនេះជាចម្បង បាន ដោយសារពន្ធលើមធ្យោបាយដឹកជញ្ជូន (ប្រហែល ២៧ ពាន់លានរៀល)។

៣) តួលេខខែសីហាបានបង្ហាញការថយចុះគួរឲ្យចាប់អារម្មណ៍ នៃអត្រាការប្រាក់កម្ចីជារៀល និងជាដុល្លារ នៅធនាគារពាណិជ្ជ។ នេះជាចម្បង គឺដោយសារតែការកែប្រែវិធីសាស្ត្រគណនាអត្រាការប្រាក់មធ្យម តាមរបៀបការថ្លឹង ដោយប្រើមេគុណ (Weight) នៃប្រភេទកម្ចីនីមួយៗប៉ុណ្ណោះ មិនមែនដោយសារក្នុងខែនេះ មានការថយចុះនៃអត្រាការប្រាក់កម្ចីនៅក្នុងប្រព័ន្ធធនាគារទេ។

៤) យោងតាមតួលេខអនុញ្ញាត សំណង់ក្នុងឆ្នាំ ២០១១នេះ ជារួម មានការងើបឡើងវិញ ជាពិសេសសំណង់ធំៗ ដូចជា ខុនដូ បុរី និងសំណង់ឧស្សាហកម្ម ប៉ុន្តែសំណង់តូចៗ មានផ្ទៃក្រឡាក្រោម ៣០០០ម$^2$ ជាសំណង់លំនៅឋានឯកជន មានការថយចុះវិញ។

- ✧ មានបញ្ហាស្រួចស្រាវមួយចំនួន ដែលកើតមានក្នុងវិស័យសំណង់ ដូចជាសំណង់មិនស្របច្បាប់ ការគេចពន្ធ និងការប្រកួតប្រជែងមិនត្រឹមត្រូវជាដើម។
- ✧ សំណង់មិនស្របច្បាប់ ជាបញ្ហាយ៉ាងធ្ងន់ធ្ងរ ជាពិសេសសំណង់ស្ថានីយប្រេងឥន្ធនៈមិនស្របច្បាប់ ដែលអាចបង្កហានិភ័យយ៉ាងគ្រោះថ្នាក់បំផុតដល់ប្រជាជនដែលរស់នៅក្បែរស្ថានីយទាំងនោះ។

### *ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖*

១) ជារួម កម្ពុជាមានឱនភាពថវិកា ដែលមានទំហំប្រហែលពី ៤-៥% នៃផលិតផលក្នុងស្រុកសរុប។ កាលពីឆ្នាំ២០០៩ ឱនភាពថវិកាជាតិមានប្រមាណ ៦,៣% នៃផលិតផលក្នុងស្រុកសរុប (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។

ឱនភាពថវិកាជាសម្ពាធលើលទ្ធភាពនៃការកសាងហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការផ្សេងទៀតនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច។ ប្រហែល ៨០% នៃឱនភាពត្រូវបានធ្វើហិរញ្ញប្បទានពីក្រៅប្រទេស ក្នុងនោះកម្ចីមានប្រហែល ៦០%។



ចំណូលពន្ធដារក្នុងស្រុកជាប្រភពចំណូលថវិកាមានចីរភាពជាង បើប្រៀបធៀបនឹងពន្ធ-គយ ដែលយោងតាមកិច្ចព្រមព្រៀងអន្តរជាតិ ត្រូវតែមានការថយចុះជាបណ្តើរៗ។ សម្រាប់ពេលបច្ចុប្បន្ន បមាណភាគនៃចំណូលពន្ធ-គយ ក្នុងចំណូលថវិកាជាតិសរុបមានប្រហែល ៥០%។ ដូច្នេះ យើងសង្កេតឃើញថា ចំណូលថវិកានៅតែមានការពឹងផ្អែកក្នុងកម្រិតខ្ពស់នៅឡើយ លើចំណូលពន្ធ-គយ។

ម្យ៉ាងវិញទៀត សមត្ថភាពប្រព័ន្ធពន្ធដារកម្ពុជាបច្ចុប្បន្ន កំពុងស្ថិតនៅទាបជាងសេចក្តីត្រូវការនៃចំណូលថវិកាជាតិ សម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍតំបន់ជនបទ ការទប់ទល់នឹងគ្រោះធម្មជាតិ និងការចំណាយលើការអភិវឌ្ឍធុរកិច្ចខ្នាតតូច និងមធ្យម តាមវិស័យផ្សេងៗ។ ក.ស.វ. យល់ថា គួរមានការសិក្សាស្រាវជ្រាវ ដោយមានការវិភាគគ្រប់ជ្រុងជ្រោយ អំពីប្រភពចំណូលពន្ធដារ ក្នុងគោលបំណង៖

ក) ពិនិត្យនិងលើកកម្ពស់តម្លាភាព ប្រសិទ្ធភាពរបបពន្ធដារ និងការប្រមូលពន្ធ

ខ) រិះរកមូលដ្ឋានប្រភពពន្ធថ្មី ដែលមិនបង្កភាពអវិជ្ជមានមកលើសេដ្ឋកិច្ច-សង្គមកិច្ច។

ជាសរុប យើងសន្និដ្ឋានថា គោលគំនិតនៃការដាក់ឲ្យមានការសិក្សាស្រាវជ្រាវអំពីប្រព័ន្ធពន្ធដារកម្ពុជា និងពិនិត្យលទ្ធភាពកំណែទម្រង់មួយចំនួន ជាកិច្ចការចាំបាច់និងចំពេលវេលា។

២) អាជ្ញាធរពាក់ព័ន្ធគួរមានវិធានការតឹងរ៉ឹង ចំពោះការអនុញ្ញាតដល់សំណង់មិនស្របច្បាប់ ទាំងសំណង់ស្ថានីយប្រេងឥន្ទនៈ ក្នុងគោលដៅ រក្សាសុវត្ថិភាពរស់នៅ ទាំងសំណង់លំនៅឋាន ក្នុងគោលដៅការពារផលប្រយោជន៍អ្នកប្រើប្រាស់។

ក្រសួងមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសសាលារាជធានីភ្នំពេញ គួរចាត់វិធានការបិទស្ថានីយប្រេងឥន្ទនៈមិនស្របច្បាប់ជាមុខរបរមួយដែលអាចបង្កហានិភ័យខ្ពស់ ក្នុងគោលដៅរក្សាសុវត្ថិភាពជូនប្រជាពលរដ្ឋ។

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧/០៩/១១<br>ម៉ោង ០៩ : ០០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងសេចក្តីព្រាងរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់តំបន់សហគមន៍ លើផ្ទៃដីទំហំ ១៥០០ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ០៨/០៩/១១<br>ម៉ោង ១៨ : ០០ នាទី | ជួបប្រជុំជាមួយឯកអគ្គរដ្ឋទូតកូរ៉េខាងជើង ដើម្បីពិភាក្សាការងារសាងសង់សារមន្ទីរសព្វទស្សន៍ (Panorama Museum) ក្នុងខេត្តសៀមរាប នៅបន្ទប់ឯកឧត្តម ប្រធាន ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៩/០៩/១១<br>ម៉ោង ០៨ : ៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងសេចក្តីព្រាងរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់តំបន់សហគមន៍ លើផ្ទៃដីទំហំ ១៥០០ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។<br>៣-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ៤ | ១២/០៩/១១<br>ម៉ោង ០៧ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលពាណិជ្ជកម្មកោះពេជ្រ ។ |
| ៥ | ១២/០៩/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេសក្រុមការងារស្ថាបត្យកម្ម និងក្រុមការងារជំនាញវប្បធម៌ ជាមួយភាគីកូរ៉េខាងជើង ដើម្បីសម្របសម្រួលការអនុវត្តគម្រោងវិនិយោគសាងសង់អគារសារមន្ទីរសព្វទស្សន៍ (Grand Panorama Museum) ក្នុងខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១១ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៦ | ១៣/០៩/១១ ម៉ោង ១៦:០០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន VINCI និង CEO ក្រុមហ៊ុន SCA ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៧ | ១៨/០៩/១១ ម៉ោង ១៩:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀង ពិសារអាហារពេលល្ងាច ជូនជាកិត្តិយស ចំពោះឯកឧត្តម Thaksin Shinawatra ក្នុងឱកាសដែលឯកឧត្តម អញ្ជើញមកចូលរួមថ្លែងបាឋកថាក្នុងវេទិកាអន្តរជាតិ នៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសណ្ឋាគារកាំបូឌីយ៉ាណា ។ |
| ៨ | ១៩/០៩/១១ ម៉ោង ០៨:០០ នាទី | ចូលរួមជាសមាជិកក្នុងវេទិកាអន្តរជាតិស្តីពី "សតវត្សរ៍អាស៊ីៈ បញ្ហាប្រឈម និងក្តីសង្ឃឹម (Asian Century: Challenges and Prospects)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានការចូលរួមធ្វើបាឋកថាដោយឥស្សរជនជាន់ខ្ពស់នៅអាស៊ីមានជាអាទិ៍ ឯកឧត្តម Jose de Venecia Jr អតីតប្រធានសភាហ្វីលីពីន និងឯកឧត្តម បណ្ឌិត Thaksin Shinawatra អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃឡង់ដ៍ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៩ | ១៩/០៩/១១ ម៉ោង ១៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបំពាក់គ្រឿងឥស្សរិយយស ជូនឥស្សរជនជាន់ខ្ពស់ និងពិធីជប់លៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ១០ | ២១/០៩/១១ ម៉ោង ១៨:៣០ នាទី | ចូលរួមក្នុងពិធីជប់លៀង ជាកិត្តិយសជូនគណៈប្រតិភូ ក្នុងឱកាសកិច្ចប្រជុំអន្តរសភាអាស៊ាន (AIPA) លើកទី៣២ នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម **កែប ជុតិមា** គណៈអភិបាលរាជធានីភ្នំពេញ និងលោកជំទាវ នៅសណ្ឋាគារអាំងទ័រកុងទីណង់តាល់ ។ |
| ១១ | ២៣/០៩/១១ ម៉ោង ០៩:០០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក MENANTEAU CEO ក្រុមហ៊ុន SCA នៅបន្ទប់ ឯកឧត្តម ប្រធាន ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១២ | ២៤/០៩/១១ ម៉ោង ១៤:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៅពហុកីឡាដ្ឋានជាតិអូឡាំពិក ។ |
| ១៣ | ២៦/០៩/១១ ម៉ោង ០៨:៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីពិសេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើបញ្ហាទឹកជំនន់ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អនុប្រធាន សមាជិក និងអគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១១

### ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧/០៩/១១ | ចូលរួមក្នុងអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញា សិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងសេចក្តីព្រាងរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់តំបន់សហគមន៍ លើផ្ទៃដីទំហំ ១៥០០ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃនាមដូនសំ ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។<br>៣-បញ្ហាផ្សេងៗ ។ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ១៩/០៩/១១ | ចូលរួមជាសមាជិកក្នុងវេទិកាអន្តរជាតិស្តីពី "សតវត្សរ៍អាស៊ី៖ បញ្ហាប្រឈម និងក្តីសង្ឃឹម (Asian Century: Challenges and Prospects)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានការចូលរួមធ្វើបាឋកថាដោយឥស្សរជនជាន់ខ្ពស់នៅអាស៊ីមានជាអាទ៍ ឯកឧត្តម Jose de Venecia Jr អតីតប្រធានសភាហ្វីលីពីន និង ឯកឧត្តម បណ្ឌិត Thaksin Shinawatra អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃឡង់ដ៍ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

### ឯកឧត្តម ឡុង ឈាង សមាជិក

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៨/០៩/១១ | ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារប្រចាំខែសីហា ឆ្នាំ២០១១ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |
| ២ | ២៣/០៩/១១ | ចូលរួមសិក្ខាសាលានៅកំពង់ចាមស្តីពីការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីវារីវប្បកម្ម។ |

### ឯកឧត្តម ង៉ាន់ ភិរុណ អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៩/០៩/១១ | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញា សិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងសេចក្តីព្រាងរបាយការណ៍ ជាតិលើកទី១ និងទី២ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់តំបន់សហគមន៍ លើផ្ទៃដីទំហំ ១៥០០ហិកតា ក្នុងតំបន់ ដែនជម្រកសត្វព្រៃនាមដូនសំ ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។<br>៣-បញ្ហាផ្សេងៗ ។ នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ២ | ១៩/០៩/១១ | ចូលរួមជាសមាជិកក្នុងវេទិកាអន្តរជាតិស្តីពី "សតវត្សរ៍អាស៊ី៖ បញ្ហាប្រឈម និងក្តីសង្ឃឹម (Asian Century: Challenges and Prospects)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានការចូលរួមធ្វើ បាឋកថាដោយឥស្សរជនជាន់ខ្ពស់នៅអាស៊ីមានជាអាទ៍ ឯកឧត្តម Jose de Venecia Jr អតីតប្រធាន សភាហ្វីលីពីន និងឯកឧត្តម បណ្ឌិត Thaksin Shinawatra អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃឡង់ដ៍ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ២៦/០៩/១១ | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីពិសេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើបញ្ហាទឹកជំនន់ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | Ék]tm Km sysamILn | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក ៖ | Ék]tm gan RrN | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអត្ថបទ ៖ | Ék]tm eGg rtmn | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច ៖ | Ék]tm mm saT | សមាជិកបម្រុង ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | elak sy vasna | ប្រធានការិយាល័យ ក.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | elak ehg sD3bBa | ប្រធានការិយាល័យ ក.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | elak nk Fara | ជំនួយការទេសរដ្ឋមន្ត្រី ប្រធាន ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in